សំណុំឯកសារស្នើសុំជំនួយគតិយុត្តិ ក្នុងរឿងក្តីស្តីពីមរតក



លិខិតស្នើសុំជំនួយគតិយុត្តិ (តាមគំរូដែលផ្តល់ដោយអង្គការអនុវត្តជំនួយគតិយុត្តិ ឬទាញយកពី គេហទំព័រសេវាសាធារណៈជាតិ សម្រាប់នីតិវិធីស្នើសុំជំនួយគតិយុត្តិ លេខកូដ 2.0000829)។




លិខិតបញ្ជាក់ថាស្ថិតក្នុងក្របខ័ណ្ឌទទួលបានជំនួយគតិយុត្តិ (ឧទាហរណ៍៖ វិញ្ញាបនបត្រគ្រួសារក្រីក្រ គ្រឿងឥស្សរិយយសមេដាយ...)។



លិខិតស្នាម និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងរឿងក្តីស្តីពីមរតក (ឧទាហរណ៍ មតកសាសន៍...)។


របៀបដាក់ស្នើសំណុំឯកសារស្នើសុំជំនួយគតិយុត្តិ



ដាក់ស្នើដោយផ្ទាល់នៅទីស្នាក់ការមជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ និងអង្គការដែលចូលរួមជំនួយគតិយុត្តិ។



ផ្ញើសំណុំឯកសារតាមរយៈសេវាប្រៃសណីយ៍។



ផ្ញើសំណុំឯកសារតាមរយៈហ្វាក់ស៍ ឬទម្រង់អេឡិចត្រូនិក។

(មាត្រា ២៩ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ)

ព័ត៌មានទំនាក់ទំនងដើម្បីស្នើសុំជំនួយគតិយុត្តិ សម្រាប់ជនជាតិភាគតិច ស្តីពីមរតក៖

មជ្ឈមណ្ឌលជំនួយគតិយុត្តិរដ្ឋ ស្ថិតក្រោមមន្ទីរយុត្តិធម៌រាជធានី ខេត្ត និងក្រុងដែលស្ថិតក្រោមមជ្ឈឹម។

អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាផ្នែកច្បាប់ ដែលចូលរួមអនុវត្តជំនួយគតិយុត្តិ។

:អសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានប្រកាសជាសាធារណៈនៅ៖

- **គេហទំព័រនីតិកម្មជាតិ**
  https://phapluat.gov.vn/
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់ក្រសួងយុត្តិធម៌**
  https://dstrogiupphaply.moj.gov.vn/all/searchOrganization
- **គេហទំព័រព័ត៌មានអេឡិចត្រូនិកស្តីពីជំនួយគតិយុត្តិនៅប្រទេសវៀតណាម**
  https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់មន្ទីរយុត្តិធម៌នៅមូលដ្ឋាន**



លោកអ្នកអាចទាក់ទងតាមមធ្យោបាយខាងក្រោម ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖

ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីជំនួយគតិយុត្តិ

១៨០០១២៣៣

(Cước gọi miễn phí)

ទាញយកកម្មវិធីទូរស័ព្ទចល័តស្តីពីជំនួយគតិយុត្តិ

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ *Android*

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ *iOS*

BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិសម្រាប់ ជនជាតិភាគតិច ស្តីពីមរតក

TRỢ GIÚP PHÁP LÝ



សិទ្ធិមរតក៖

- បុគ្គលមានសិទ្ធិធ្វើមតកសាសន៍ ដើម្បីកំណត់អំពីទ្រព្យសម្បត្តិរបស់ខ្លួន។
- បុគ្គលមានសិទ្ធិទុកទ្រព្យសម្បត្តិរបស់ខ្លួនជូនអ្នកទទួលមរតកតាមច្បាប់។
- បុគ្គលមានសិទ្ធិទទួលមរតកតាមមតកសាសន៍ ឬតាមច្បាប់។
- អ្នកទទួលមរតកដែលមិនមែនជាបុគ្គល មានសិទ្ធិទទួលមរតកតាមមតកសាសន៍។

(មាត្រា ៦០៩ នៃក្រមរដ្ឋប្បវេណី)

មតកសាសន៍៖

មតកសាសន៍ គឺជាការបង្ហាញឆន្ទៈរបស់បុគ្គល ក្នុងគោលបំណងផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនជូនអ្នកដទៃ ក្រោយពេលស្លាប់។ មតកសាសន៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ បើមិនអាចធ្វើមតកសាសន៍ជាលាយលក្ខណ៍អក្សរបានទេ អាចធ្វើមតកសាសន៍ដោយផ្ទាល់មាត់។

(មាត្រា ៦២៤ មាត្រា ៦២៧ នៃក្រមរដ្ឋប្បវេណី)

មរតកតាមច្បាប់៖

មរតកតាមច្បាប់ គឺជាមរតកតាមលំដាប់អ្នកទទួលមរតក លក្ខខណ្ឌ និងលំដាប់នៃការទទួលមរតក ដែលច្បាប់កំណត់។ អ្នកទទួលមរតកតាមច្បាប់ ត្រូវបានបែងចែកជាលំដាប់អ្នកទទួលមរតក៖

- លំដាប់ទី១ រួមមាន៖ ភរិយា ស្វាមី ឪពុកបង្កើត ម្តាយបង្កើត ឪពុកចិញ្ចឹម ម្តាយចិញ្ចឹម កូនបង្កើត កូនចិញ្ចឹមរបស់អ្នកស្លាប់។
- លំដាប់ទី២ រួមមាន៖ ជីតាខាងឪពុក ជីដូនខាងឪពុក ជីតាខាងម្តាយ ជីដូនខាងម្តាយ បងប្អូនបង្កើតរបស់អ្នកស្លាប់។ ចៅបង្កើតរបស់អ្នកស្លាប់ ដែលអ្នកស្លាប់ជាជីតាខាងឪពុក ជីដូនខាងឪពុក ជីតាខាងម្តាយ ជីដូនខាងម្តាយ។
- លំដាប់ទី៣ រួមមាន៖ ជីទួតខាងឪពុក ជីទួតខាងម្តាយរបស់អ្នកស្លាប់។ ពូ មីង អុំ បង្កើតរបស់អ្នកស្លាប់។ ក្មួយបង្កើតរបស់អ្នកស្លាប់ ដែលអ្នកស្លាប់ជាពូ មីង អុំ បង្កើត។ ចៅទួតបង្កើតរបស់អ្នកស្លាប់ ដែលអ្នកស្លាប់ជាជីទួតខាងឪពុក ជីទួតខាងម្តាយ។



ជំនួយគតិយុត្តិសម្រាប់ជនជាតិភាគតិចស្តីពីមរតក

នៅពេលជួបប្រទះបញ្ហាជាប់ពាក់ព័ន្ធនឹងច្បាប់ស្តីពីមរតក ជនជាតិភាគតិចដែលស្ថិតក្នុងករណីដូចខាងក្រោម មានសិទ្ធិស្នើសុំឲ្យរដ្ឋផ្តល់ជំនួយគតិយុត្តិដោយឥតគិតថ្លៃ៖

- អ្នកមានសតុណចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងក្របខណ្ឌគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានស្ថានភាពសេដ្ឋកិច្ច - សង្គមលំបាកជាពិសេស។
- អ្នកដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ក្នុងករណីជាអ្នកត្រូវចោទប្រកាន់ អ្នកត្រូវបានស្នើឲ្យប្តឹង អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកចុងចោទ ជនរងគ្រោះ សាក្សី អ្នកដែលកំពុងស្ថិតក្រោមការអនុវត្តវិធានការដោះស្រាយបង្វែរទិស និងជាទណ្ឌិតក្នុងនីតិវិធីព្រហ្មទណ្ឌ។
- អ្នកចុងចោទដែលស្ថិតក្នុងក្របខ័ណ្ឌគ្រួសារបៀតក្រីក្រ។
- អ្នករងគ្រោះអ្នកដែលកំពុងស្ថិតក្នុងដំណើរការកំណត់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំរួមដំណើរជាមួយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីមួយក្នុងចំណោមករណីដូចខាងក្រោមនេះ មានការលំបាកអំពីហិរញ្ញវត្ថុ៖ i) ឪពុកបង្កើត ម្តាយបង្កើត ប្តី ប្រពន្ធ កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ក្នុងការចិញ្ចឹមបីបាច់យុទ្ធជនពលីកាលពីនៅតូច; ii) អ្នកដែលរងផលប៉ះពាល់ដោយសារធាតុពុលពណ៌ទឹកក្រូច; iii) មនុស្សចាស់; iv) ជនមានពិការភាព; v) ជនរងគ្រោះក្នុងករណីអំពើហិង្សាគ្រួសារ; vi) អ្នកជ្រាប HIV។

លក្ខខណ្ឌលំបាកអំពីហិរញ្ញវត្ថុរបស់អ្នកទទួលជំនួយគតិយុត្តិ គឺជាមុខសញ្ញាស្ថិតក្នុងគ្រួសារបៀតក្រីក្រ ឬជាមុខសញ្ញាដែលកំពុងទទួលប្រាក់ឧបត្ថម្ភសង្គមប្រចាំខែ តាមបទប្បញ្ញត្តិនៃច្បាប់។

ទម្រង់ជំនួយគតិយុត្តិ ក្នុងរឿងក្តីស្តីពីមរតក

តាមបទប្បញ្ញត្តិនៅមាត្រា ២៧ ៣១ ៣២ ៣៣ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ ទម្រង់ជំនួយគតិយុត្តិរួមមាន៖

ការប្រឹក្សាច្បាប់៖



អ្នកអនុវត្តជំនួយគតិយុត្តិ ណែនាំ ផ្តល់មតិ ជួយតាក់តែងលិខិតស្នាមដែលពាក់ព័ន្ធនឹងវិវាទ ពាក្យបណ្តឹង និងបញ្ជាជាប់ពាក់ព័ន្ធនឹងច្បាប់ ណែនាំជួយភាគីនានាឲ្យផ្សះផ្សា ចរចា និងឯកភាពគ្នាលើទិសដៅដោះស្រាយរឿងក្តីស្តីពីមរតក (ឧទាហរណ៍ អំពីមតកសាសន៍ មរតកតាមច្បាប់ ការតាក់តែងមតកសាសន៍ វិវាទ ពាក្យបណ្តឹង...)។

ការចូលរួមក្នុងនីតិវិធីតុលាការ៖



ភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយគតិយុត្តិ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ នៅចំពោះមុខស្ថាប័នដែលដំណើរការនីតិវិធីតុលាការ ដូចជា៖ ស្ថាប័ននគរបាលអយ្យការ តុលាការ។

ការតំណាងក្រៅនីតិវិធីតុលាការ៖



ភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយគតិយុត្តិ ធ្វើជាតំណាងក្រៅនីតិវិធីតុលាការ នៅចំពោះមុខស្ថាប័នរដ្ឋមានសមត្ថកិច្ច (ឧទាហរណ៍ គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់...) ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីស្តីពីមរតក។